# មហាសន្និបាត

ការចែកចាយ៖ ជាទូទៅ
ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤

ឯកសារដើម៖ ភាសាអង់គ្លេស

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**
**សម័យប្រជុំទីហាសិបប្រាំពីរ**
ថ្ងៃទី៩ ខែកញ្ញា - ថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៤
របៀបវារៈទី ៦
**ការពិនិត្យឡើងវិញជាសកលតាមកាលកំណត់**

## របាយការណ៍របស់ក្រុមការងារស្ដីពី ការពិនិត្យឡើងវិញជាសកលតាមកាលកំណត់*

## កម្ពុជា

### ឯកសារភ្ជាប់

### ទស្សនៈចំពោះសេចក្ដីសន្និដ្ឋាន និង/ឬអនុសាសន៍ ការប្ដេជ្ញាចិត្តដោយស្ម័គ្រចិត្ត និងការឆ្លើយតបរបស់រដ្ឋដែលស្ថិតក្រោមការពិនិត្យឡើងវិញ

* ឯកសារបច្ចុប្បន្នត្រូវបានផ្សព្វផ្សាយដោយគ្មានការកែសម្រួលផ្លូវការឡើយ។

១. បន្ទាប់ពីការពិចារណាលើអនុសាសន៍ទាំង ២៧៥ ដែលរដ្ឋសមាជិកអង្គការសហប្រជាជាតិចំនួន ១០០ បានផ្តល់ជូនកម្ពុជា ក្នុងអំឡុងការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ ជុំទី ៤ នៅទីក្រុងហ្សឺណែវ ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៤ រាជរដ្ឋាភិបាលកម្ពុជាសូមបញ្ជាក់ដូចខាងក្រោម។

# I. ទទួលយក អនុសាស្រ្តចំនួន ២៣២

២. ១៣៩.១២, ១៣៩.១៣, ១៣៩.១៩, ១៣៩.២០, ១៣៩.២១, ១៣៩.២២, ១៣៩.២៤, ១៣៩.២៥, ១៣៩.២៦, ១៣៩.២៧, ១៣៩.២៨, ១៣៩.២៩, ១៣៩.៣០, ១៣៩.៣១, ១៣៩.៣២, ១៣៩.៣៣, ១៣៩.៣៤, ១៣៩.៣៥, ១៣៩.៣៦, ១៣៩.៣៧, ១៣៩.៣៨, ១៣៩.៣៩, ១៣៩.៤០, ១៣៩.៤២, ១៣៩.៤៥, ១៣៩.៤៦, ១៣៩.៤៧, ១៣៩.៤៨, ១៣៩.៤៩, ១៣៩.៥២, ១៣៩.៥៣, ១៣៩.៥៤, ១៣៩.៥៥, ១៣៩.៥៧, ១៣៩.៥៩, ១៣៩.៦០, ១៣៩.៦១, ១៣៩.៦២, ១៣៩.៦៣, ១៣៩.៦៤, ១៣៩.៦៥, ១៣៩.៦៧, ១៣៩.៦៨, ១៣៩.៦៩, ១៣៩.៧០, ១៣៩.៧១, ១៣៩.៧២, ១៣៩.៧៣, ១៣៩.៧៤, ១៣៩.៧៥, ១៣៩.៧៧, ១៣៩.៧៨, ១៣៩.៧៩, ១៣៩.៨០, ១៣៩.៨១, ១៣៩.៨២, ១៣៩.៨៣, ១៣៩.៨៤, ១៣៩.៨៥, ១៣៩.៨៦, ១៣៩.៨៩, ១៣៩.៩០, ១៣៩.៩១, ១៣៩.៩៥, ១៣៩.៩៦, ១៣៩.៩៧, ១៣៩.៩៨, ១៣៩.៩៩, ១៣៩.១០០, ១៣៩.១០១, ១៣៩.១០២, ១៣៩.១០៣, ១៣៩.១០៤, ១៣៩.១០៥, ១៣៩.១០៦, ១៣៩.១០៧, ១៣៩.១០៨, ១៣៩.១០៩, ១៣៩.១១០, ១៣៩.១១៤, ១៣៩.១១៥, ១៣៩.១១៦, ១៣៩.១១៧, ១៣៩.១១៨, ១៣៩.១១៩, ១៣៩.១២០, ១៣៩.១២១, ១៣៩.១២២, ១៣៩.១២៣, ១៣៩.១២៤, ១៣៩.១២៥, ១៣៩.១២៦, ១៣៩.១២៧, ១៣៩.១២៨, ១៣៩.១២៩, ១៣៩.១៣០, ១៣៩.១៣១, ១៣៩.១៣២, ១៣៩.១៣៣, ១៣៩.១៣៤, ១៣៩.១៣៥, ១៣៩.១៣៦, ១៣៩.១៣៧, ១៣៩.១៣៨, ១៣៩.១៣៩, ១៣៩.១៤០, ១៣៩.១៤១, ១៣៩.១៤២, ១៣៩.១៤៣, ១៣៩.១៤៤, ១៣៩.១៤៥, ១៣៩.១៤៦, ១៣៩.១៤៧, ១៣៩.១៤៨, ១៣៩.១៤៩, ១៣៩.១៥០, ១៣៩.១៥១, ១៣៩.១៥២, ១៣៩.១៥៣, ១៣៩.១៥៥, ១៣៩.១៥៦, ១៣៩.១៥៧, ១៣៩.១៥៨, ១៣៩.១៥៩, ១៣៩.១៦០, ១៣៩.១៦១, ១៣៩.១៦២, ១៣៩.១៦៣, ១៣៩.១៦៤, ១៣៩.១៦៥, ១៣៩.១៦៦, ១៣៩.១៦៧, ១៣៩.១៦៨, ១៣៩.១៧២, ១៣៩.១៧៣, ១៣៩.១៧៤, ១៣៩.១៧៥, ១៣៩.១៧៦, ១៣៩.១៧៧, ១៣៩.១៧៨, ១៣៩.១៧៩, ១៣៩.១៨០, ១៣៩.១៨១, ១៣៩.១៨២, ១៣៩.១៨៣, ១៣៩.១៨៤, ១៣៩.១៨៥, ១៣៩.១៨៦, ១៣៩.១៨៧, ១៣៩.១៨៨, ១៣៩.១៨៩, ១៣៩.១៩០, ១៣៩.១៩១, ១៣៩.១៩២, ១៣៩.១៩៣, ១៣៩.១៩៤, ១៣៩.១៩៥, ១៣៩.១៩៦, ១៣៩.១៩៩, ១៣៩.២០០, ១៣៩.២០១, ១៣៩.២០២, ១៣៩.២០៣, ១៣៩.២០៤, ១៣៩.២០៥, ១៣៩.២០៦, ១៣៩.២០៧, ១៣៩.២០៨,

១៣៩.២១២, ១៣៩.២១៣, ១៣៩.២១៤, ១៣៩.២១៥, ១៣៩.២១៦, ១៣៩.២១៧, ១៣៩.២១៨, ១៣៩.២១៩, ១៣៩.២២០, ១៣៩.២២១, ១៣៩.២២២, ១៣៩.២២៣, ១៣៩.២២៤, ១៣៩.២២៥, ១៣៩.២២៦, ១៣៩.២២៧, ១៣៩.២២៨, ១៣៩.២២៩, ១៣៩.២៣០, ១៣៩.២៣១, ១៣៩.២៣២, ១៣៩.២៣៣, ១៣៩.២៣៤, ១៣៩.២៣៥, ១៣៩.២៣៦, ១៣៩.២៣៧, ១៣៩.២៣៨, ១៣៩.២៣៩, ១៣៩.២៤០, ១៣៩.២៤១, ១៣៩.២៤២, ១៣៩.២៤៣, ១៣៩.២៤៤, ១៣៩.២៤៥, ១៣៩.២៤៦, ១៣៩.២៤៧, ១៣៩.២៤៨, ១៣៩.២៤៩, ១៣៩.២៥០, ១៣៩.២៥១, ១៣៩.២៥២, ១៣៩.២៥៣, ១៣៩.២៥៤, ១៣៩.២៥៥, ១៣៩.២៥៦, ១៣៩.២៥៧, ១៣៩.២៥៨, ១៣៩.២៥៩, ១៣៩.២៦០, ១៣៩.២៦១, ១៣៩.២៦២, ១៣៩.២៦៣, ១៣៩.២៦៤, ១៣៩.២៦៥, ១៣៩.២៦៦, ១៣៩.២៦៧, ១៣៩.២៦៨, ១៣៩.២៦៩, ១៣៩.២៧០, ១៣៩.២៧១, ១៣៩.២៧២, ១៣៩.២៧៣, ១៣៩.២៧៤, ១៣៩.២៧៥។

## II. កត់សម្គាល់ អនុសាសន៍ចំនួន ៤៣

៣. ១៣៩.១, ១៣៩.២, ១៣៩.៣, ១៣៩.៤, ១៣៩.៥, ១៣៩.៦, ១៣៩.៧, ១៣៩.៨, ១៣៩.៩, ១៣៩.១០, ១៣៩.១១, ១៣៩.១៤, ១៣៩.១៥, ១៣៩.១៦, ១៣៩.១៧, ១៣៩.១៨, ១៣៩.២៣, ១៣៩.៤១, ១៣៩.៤៣, ១៣៩.៤៤, ១៣៩.៥០, ១៣៩.៥១, ១៣៩.៥៦, ១៣៩.៥៨, ១៣៩.៦៦, ១៣៩.៧៦, ១៣៩.៨៧, ១៣៩.៨៨, ១៣៩.៩២, ១៣៩.៩៣, ១៣៩.៩៤, ១៣៩.១១១, ១៣៩.១១២, ១៣៩.១១៣, ១៣៩.១៥៤, ១៣៩.១៦៩, ១៣៩.១៧០, ១៣៩.១៧១, ១៣៩.១៩៧, ១៣៩.១៩៨, ១៣៩.២០៩, ១៣៩.២១០, ១៣៩.២១១។

### មូលហេតុសម្រាប់ការកត់សម្គាល់អនុសាសន៍

**១. ការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកលិខិតុបករណ៍អន្តរជាតិ (អនុសាសន៍លេខ ១៣៩.១, ១៣៩.២, ១៣៩.៣, ១៣៩.៤, ១៣៩.៥, ១៣៩.៦, ១៣៩.៧, ១៣៩.៨, ១៣៩.៩, ១៣៩.១០, ១៣៩.១១, ១៣៩.១៤, ១៣៩.១៥, ១៣៩.១៦, ១៣៩.១៧ និង ១៣៩.១៨)**

៣. ព្រះរាជាណាចក្រកម្ពុជាបានបង្ហាញការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះវិស័យសិទ្ធិមនុស្ស តាមរយៈការផ្តល់សច្ចាប័ន និងការចូលជាសមាជិកសន្ធិសញ្ញាសិទ្ធិមនុស្ស និងលិខិតុបករណ៍អន្តរជាតិនានា។ បន្ថែមលើនេះ ប្រទេសកម្ពុជាបានពិនិត្យ និងសិក្សាដោយយកចិត្តទុកដាក់ចំពោះលទ្ធភាពផ្តល់សច្ចាប័នលិខិតុបករណ៍អន្តរជាតិផ្សេងទៀត។ ទោះជាយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាល និងស្ថាប័នជាតិដទៃទៀតបានខិតខំប្រឹងប្រែងរៀបចំយន្តការនានា ទាំងក្នុងក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌស្ថាប័ន រួមទាំងការពង្រឹងការអនុវត្ត ដែល

ធានាដល់ការលើកកម្ពស់ និងការគាំពារសិទ្ធិមនុស្សនៅកម្ពុជាប្រកបដោយប្រសិទ្ធភាព។ ឧទាហរណ៍ នៅកម្ពុជា គ្មានការផ្តន្ទាទោសប្រហារជីវិតឡើយ ហើយកំណែទម្រង់ច្បាប់ និងតុលាការនៅតែជាយុទ្ធសាស្ត្រអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយមានគោលបំណងពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពច្បាប់ និងប្រព័ន្ធតុលាការនៅក្នុងប្រទេស។

## ២. ការអនុវត្តអនុសាសន៍ទាំង ១០ របស់អ្នករាយការណ៍ពិសេស (អនុសាសន៍លេខ ១៣៩.២៣)

៥. ប្រទេសកម្ពុជាតែងតែបានផ្តល់កិច្ចសហប្រតិបត្តិការល្អ ជាមួយអ្នករាយការណ៍ពិសេស ទោះជាយ៉ាងណាក្តី សំណើឱ្យអនុវត្តអនុសាសន៍ទាំងអស់របស់គាត់ គឺមិនសមហេតុផលឡើយ ដោយសារអនុសាសន៍មួយចំនួនបង្កអន្តរាយចំពោះអធិបតេយ្យភាព និងឯករាជ្យភាពរបស់ប្រព័ន្ធតុលាការកម្ពុជា ដែលកម្ពុជាមិនអាចទទួលយកបាននោះឡើយ ដោយសារការចោទប្រកាន់ទាំងអស់ ត្រូវបានធ្វើឡើងដោយអនុលោមទៅតាមនីតិវិធីច្បាប់ ដោយមិនពាក់ព័ន្ធនឹងនយោបាយឡើយ។

## ៣. ការពង្រឹងតួនាទីរបស់ស្ថាប័នជាតិសិទ្ធិមនុស្ស (អនុសាសន៍លេខ ១៣៩.៤១)

៦. ប្រទេសកម្ពុជាមិនទាន់បានបង្កើតស្ថាប័នជាតិសិទ្ធិមនុស្សទៅតាមច្បាប់ ដោយអនុលោមទៅតាមគោលការណ៍ទីក្រុងប៉ារីសនៅឡើយ។

## ៤. ការបង្កើតច្បាប់ប្រឆាំងអំពើរើសអើង (អនុសាសន៍លេខ ១៣៩.៤៣ និង ១៣៩.៤៤)

៧. ប្រទេសកម្ពុជាបានអនុម័ត និងអនុវត្តគោលការណ៍ពាក់ព័ន្ធនឹងការមិនរើសអើង ដូចមានចែងក្នុងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញរបស់ខ្លួន ដែលចែងថា ប្រទេសកម្ពុជាទទួលស្គាល់ និងគោរពធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ UDHR ព្រមទាំងសន្ធិសញ្ញា និងអនុសញ្ញាទាំងអស់ទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ។ បន្ថែមពីលើនេះ មាត្រានៃរដ្ឋធម្មនុញ្ញនេះចែងថា ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ ក្រមព្រហ្មទណ្ឌ (សូមមើលផ្នែកទី២ ការរើសអើង នៃជំពូកទី៥ ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ ចាប់ពីមាត្រា ២៦៥ ទៅមាត្រា ២៧៣) កំណត់ជាបទល្មើសព្រហ្មទណ្ឌចំពោះអំពើរើសអើងជាក់លាក់។

## ៥. ការស៊ើបអង្កេតករណីទារុណកម្ម (អនុសាសន៍លេខ ១៣៩.៥០ និង ១៣៩.៥១)

៨. រាល់ការស៊ើបអង្កេតទៅលើបទល្មើសព្រហ្មទណ្ឌទាំងអស់ ត្រូវបានអនុវត្តដោយយកចិត្តទុកដាក់ និងហ្មត់ចត់ ដោយផ្អែកលើភស្តុតាង និងដោយអនុលោមទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ជាធរមាន។ បន្ថែមលើនេះ ក្នុងនាមជារដ្ឋភាគីនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្ស

ធម៌ ឬបន្ថោកបន្ទាប និងពិធីសារបន្ថែមនៃអនុសញ្ញានេះ ប្រទេសកម្ពុជាប្រកាន់យ៉ាងខ្ជាប់ខ្ជួនទៅតាមកាតព្វកិច្ច ដែលកំណត់ដោយលិខិតុបករណ៍ទាំងនេះ។ ដោយប្រកាន់ខ្ជាប់ខ្ជួនទៅតាមកាតព្វកិច្ចទាំងនេះ ប្រទេសកម្ពុជាបានបង្កើតគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្ម ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប នៅឆ្នាំ២០១៧។ ពាក់ព័ន្ធនឹងការទប់ស្កាត់ទារុណកម្ម និងការប្រព្រឹត្តមិនគប្បី ដែលកើតឡើងក្នុងមន្ទីរឃុំឃាំងរបស់មន្ត្រីនគរបាល មាត្រា៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា ការបង្ខិតបង្ខំ ឬការធ្វើបាបលើរូបរាងកាយត្រូវហាមឃាត់ដាច់ខាត។ បន្ថែមលើនេះ នៅក្រោមបទប្បញ្ញត្តិដូចគ្នានេះដែរ រាល់ការសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។ លើសពីនេះ ប្រទេសកម្ពុជាមានក្រមនីតិវិធីព្រហ្មទណ្ឌ ដែលកំណត់នីតិវិធី នៅពេលដែលជនម្នាក់ស្ថិតនៅក្រោមការឃុំឃាំងរបស់មន្ត្រីនគរបាល (មាត្រា ៩៦-១០៤)។ ប្រទេសកម្ពុជាមានច្បាប់គ្រប់គ្រាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងទម្រង់នានានៃទារុណកម្ម និងការប្រព្រឹត្តមិនគប្បីនៅក្នុងមន្ទីរឃុំឃាំង ឧទាហរណ៍ ច្បាប់ឆ្នាំ២០១១ ស្តីពីពន្ធនាគារ (មាត្រា ២៥ និង ៥៣) នីតិវិធីពន្ធនាគារឆ្នាំ២០០៣ (លេខ ៨) និងក្រមប្រតិបត្តិសម្រាប់ឆ្មាំពន្ធនាគារឆ្នាំ២០០៥។

## ៦. អំពើពុករលួយ និងនិទណ្ឌភាព (អនុសាសន៍លេខ ១៣៩.៥៦)

៩. គោលបំណងជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា គឺដើម្បីជំរុញ និងពង្រឹងភាពស្អាតស្អំ សុចរិតភាព ទំនុកចិត្តលើរដ្ឋបាលសាធារណៈ នីតិរដ្ឋ និងប្រយុទ្ធប្រឆាំងបន្ថែមទៀតចំពោះភាពអយុត្តិធម៌សង្គម ដែលជាគន្លឹះសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយបរិយាបន្ន និងចីរភាព ស្ថិរភាពសង្គម សណ្តាប់ធ្នាប់សាធារណៈ និងសុខដុមនីយកម្មនៅក្នុងសង្គម។ ក្នុងន័យនេះ ប្រទេសកម្ពុជាបាន និងកំពុងផ្តោតការយកចិត្តទុកដាក់ទៅលើកិច្ចការជាច្រើន រួមមានជាអាទិ៍ ការជំរុញភាពយុត្តិធម៌ និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់របស់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីតុលាការ ជាពិសេស ការពង្រឹងប្រសិទ្ធភាពនៃដំណើរការនីតិវិធីតុលាការ សុចរិតភាព វិជ្ជាជីវៈ និងក្រមសីលធម៌របស់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីតុលាការ ព្រមទាំងការពង្រឹងយន្តការអធិការកិច្ច និងទណ្ឌកម្ម។

## ៧. ការស៊ើបអង្កេតការរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តនៅក្នុងរបបពីអតីតកាល (អនុសាសន៍លេខ ១៣៩.៥៨)

១០. អនុសាសន៍នេះមានលក្ខណៈទូលាយខ្លាំង និងមិនបញ្ជាក់អំពីរបបជាក់លាក់ឡើយ។ ប្រទេសកម្ពុជាបានឆ្លងកាត់របបជាច្រើននៅមុនពេល និងក្រោយពេលរបបកម្ពុជាប្រជាធិបតេយ្យ ពោលគឺ របបខ្មែរក្រហម។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបញ្ចប់ការស៊ើបអង្កេត និងវិនិច្ឆ័យសំណុំរឿងទាំងប្រាំពីរ ហើយនៅពេលបច្ចុប្បន្ន កំពុងអនុវត្តមុខងារដែលនៅសេសសល់។

## ៨. ការបង្កើតយន្តការដោះស្រាយវិវាទដីធ្លី (អនុសាសន៍លេខ ១៣៩.៦៦ និង ១៣៩.១៧១)

១១. ព្រះរាជាណាចក្រកម្ពុជាបានរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីទទួលស្គាល់ ធានា និងការពារសិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋ។ នៅកម្ពុជា មានយន្តការពីរដើម្បីដោះស្រាយវិវាទដីធ្លី រួមមាន យន្តការដោះស្រាយវិវាទដោយប្រព័ន្ធតុលាការ និងក្រៅប្រព័ន្ធតុលាការ ដោយផ្អែកលើគោលការណ៍នៃច្បាប់ពាក់ព័ន្ធ ដោយគ្មានការបង្ខិតបង្ខំ ការគំរាមកំហែង ឬការបំភិតបំភ័យពីភាគីណាមួយឡើយ។

## ៩. ការដោះលែងអ្នកនយោបាយ និងអ្នកការពារសិទ្ធិមនុស្ស (អនុសាសន៍លេខ ១៣៩.៧៦, ១៣៩.១១១, ១៣៩.១១២ និង ១៣៩.១១៣)

១២. សូមកត់សម្គាល់ថា អំណាចតុលាការ គឺជាអំណាចឯករាជ្យ និងគ្មានផ្នែកណាមួយនៃអំណាចនីតិបញ្ញត្តិ ឬអំណាចនីតិប្រតិបត្តិអាចជ្រៀតជ្រែកនឹងការងាររបស់អំណាចតុលាការ ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជា។ ដូចគ្នានឹងប្រទេស និងប្រព័ន្ធច្បាប់ឯទៀតនៅក្នុងពិភពលោកនេះដែរ សេរីភាពខាងការបញ្ចេញមតិគឺត្រូវមានការគោរពចំពោះសិទ្ធិរបស់អ្នកដទៃ។ ការប្រើប្រាស់សិទ្ធិ និងសេរីភាពប្រជាធិបតេយ្យមិនអាចប៉ះពាល់ដល់នីតិរដ្ឋបានឡើយ ហើយប្រទេសកម្ពុជាសូមបញ្ជាក់សារជាថ្មីថា គោលការណ៍នេះត្រូវតែមានការអនុវត្តដោយស្មើភាពគ្នាចំពោះជនគ្រប់រូប ដោយមិនគិតអំពីសាវតារ ការងារ និងតួនាទីក្នុងសង្គមរបស់ពួកគេឡើយ។ សម្ព័ន្ធភាព និងឋានៈសង្គម ក្នុងនាមជាក្រុម ឬសកម្មជន ឬសហជីព ខាងនយោបាយ ឬមនោគមវិជ្ជា មិនអាចបម្រើ ឬទាមទារសិទ្ធិពិសេស ឬអភ័យឯកសិទ្ធិ ដើម្បីប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬបទមជ្ឈិម ដូចមានចែងក្នុងច្បាប់នោះឡើយ។ ចំណាត់ការផ្លូវច្បាប់ចំពោះគណបក្សនយោបាយណាមួយ ឬបុគ្គលណាម្នាក់ ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដូចជា អំពើក្បត់ជាតិ និងអំពើសមគំនិត ឬការរំលោភច្បាប់ គឺជាដំណើរការជាធម្មតានៅក្នុងរដ្ឋប្រជាធិបតេយ្យ ដោយប្រកាន់ខ្ជាប់ខ្ជួនទៅតាមគោលការណ៍នីតិរដ្ឋ និងដោយមានបំណងពង្រឹងដំណើរការប្រជាធិបតេយ្យ ព្រមទាំងការពារសន្តិភាព និងស្ថិរភាព ដែលជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរយៈពេលវែង និងប្រកបដោយចីរភាព។ អំពើក្បត់ជាតិ ចារកម្ម និងសមគំនិតជាមួយអំណាចបរទេសមួយ ដែលតស៊ូមតិឱ្យមានការផ្តួលរំលំរដ្ឋាភិបាលស្របច្បាប់ ត្រូវតែទទួលរងទណ្ឌកម្មធ្ងន់ធ្ងរដូចមានចែងក្នុងច្បាប់របស់ប្រទេសទាំងអស់ ហើយប្រទេសកម្ពុជាក៏ដូច្នេះដែរ។

## ១០. វិសោធនកម្ម និងនិរាករណ៍ច្បាប់ និងអនុក្រឹត្យ (អនុសាសន៍លេខ ១៣៩.៨៧)

១៣. ក្រសួងយុត្តិធម៌បានបង្កើតក្រុមការងារសិក្សា និងពិនិត្យឡើងវិញទៅលើច្បាប់សំខាន់ៗទាំងបួនសម្រាប់វិស័យយុត្តិធម៌ ដើម្បីពង្រឹងប្រសិទ្ធភាព និងគុណភាពនៃច្បាប់នោះសំដៅធានាសង្គតិភាព សុខដុមនីយកម្មផ្លូវច្បាប់ ការអភិវឌ្ឍឌីជីថលូបនីយកម្ម និង

ការអភិវឌ្ឍថ្មីៗរបស់សង្គម។ ច្បាប់សំខាន់ៗទាំងបួននេះ គឺ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និងនីតិវិធីក្រមរដ្ឋប្បវេណី។

១៤. អនុក្រឹត្យស្តីពី ការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ (NIGs) មិនទាន់ត្រូវបានអនុវត្តនៅឡើយ។ អនុក្រឹត្យនេះត្រូវបានរៀបចំឡើងក្នុងលក្ខណៈដែលមានតម្លាភាព និងមានការរៀបចំការពិគ្រោះយោបល់ជាមួយអ្នកជំនាញនៅក្នុងវិស័យទូរគមនាគមន៍ ប្រតិបត្តិករឯកជន និងស្ថាប័នពាក់ព័ន្ធ។ អនុក្រឹត្យនេះរួមចំណែកចំពោះការការពារសហគមន៍នានានៅក្នុងលំហបច្ចេកវិទ្យា និងបរិយាកាសអនឡាញដែលមានដែលកាន់តែល្អប្រសើរ ក្នុងន័យពង្រឹង និងគ្រប់គ្រងការភ្ជាប់ប្រព័ន្ធអ៊ីនធឺណិត សន្តិសុខជាតិ ការប្រមូលពន្ធ សណ្តាប់ធ្នាប់សង្គម និងវប្បធម៌ជាតិ។ ការបង្កើតអនុក្រឹត្យនេះក៏ស្របនឹងនិយាមអន្តរជាតិផងដែរ ជាពិសេស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ បន្ថែមពីលើនេះ NIGs ត្រូវបានបង្កើតនៅស្ទើរតែគ្រប់ប្រទេស ហើយប្រទេសកម្ពុជាក៏ដូច្នេះដែរ។

## ១១. សេរីភាពនៃការបញ្ចេញមតិ និងការជួបប្រជុំ (អនុសាសន៍លេខ ១៣៩.៨៨)

១៥. ក្រមព្រហ្មទណ្ឌមិនរឹតបន្តឹងសេរីភាពនៃការបញ្ចេញមតិ និងការជួបប្រជុំឡើយ។ រដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៩ ចែង និងធានាសេរីភាពនេះ។ ការអនុម័តច្បាប់នេះ គឺដើម្បីធានានូវសេរីភាពនៃការបញ្ចេញមតិតាមរយៈការធ្វើបាតុកម្មដោយសន្តិវិធី ប៉ុន្តែមិនត្រូវប្រើសិទ្ធិនេះក្នុងលក្ខណៈរំលោភបំពានដែលជះឥទ្ធិពលលើសិទ្ធិ សេរីភាព និងកិត្តិយសរបស់អ្នកដទៃ ប្រពៃណីទំនៀមទម្លាប់ដ៏ល្អរបស់សង្គមជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិឡើយ។ សូមកត់សម្គាល់ថា សេរីភាពនៃការបញ្ចេញមតិត្រូវមានការគោរពចំពោះសិទ្ធិរបស់អ្នកដទៃ និងសណ្តាប់ធ្នាប់សាធារណៈ ដែលដូចគ្នានឹងប្រទេស និងប្រព័ន្ធច្បាប់ឯទៀតនៅក្នុងពិភពលោកនេះដែរ។ ការប្រើប្រាស់សិទ្ធិ និងសេរីភាពប្រជាធិបតេយ្យមិនអាចប៉ះពាល់ដល់នីតិរដ្ឋបានឡើយ ហើយកម្ពុជាសូមបញ្ជាក់សារជាថ្មីថា គោលការណ៍នេះត្រូវតែអនុវត្តដោយស្មើភាពគ្នាចំពោះជនគ្រប់រូប ដោយមិនគិតពីសាវតារ និងឋានៈរបស់ពួកគេឡើយ។

១៦. កាលពីអតីតកាល ក្រសួងព័ត៌មានបានលុបចោលអាជ្ញាប័ណ្ណរបស់ប្រព័ន្ធផ្សព្វផ្សាយមួយចំនួនតូច ដោយសារប្រព័ន្ធផ្សព្វផ្សាយទាំងនោះបានរំលោភច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចព្រមព្រៀងរបស់ពួកគេជាមួយក្រសួងព័ត៌មាន ហើយក្រសួងត្រូវចាត់វិធានការផ្លូវច្បាប់លើអ្នកសារព័ត៌មានទាំងឡាយទៅតាមអង្គហេតុ និងច្បាប់ ដោយអនុលោមទៅតាមគោលការណ៍នីតិរដ្ឋ ដែលប្រទេសទាំងអស់ត្រូវប្រកាន់ខ្ជាប់ខ្ជួនតាម។

## ១២. ប្រព័ន្ធផ្សព្វផ្សាយ (អនុសាសន៍លេខ ១៣៩.៩២, ១៣៩.៩៣ និង ១៣៩.៩៤)

១៧. រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាចិត្តមុតមាំក្នុងការលើកកម្ពស់ប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស សេរីភាពនៃសារព័ត៌មាន និងការផ្សព្វផ្សាយ ស្របតាមមាត្រា ៣១ និងមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា និងដោយអនុលោមទៅតាមច្បាប់ ស្តីពី

របបសារព័ត៌មាន ឆ្នាំ១៩៩៥។ អ្នកសារព័ត៌មាននៅកម្ពុជាអាចអនុវត្តវិជ្ជាជីវៈរបស់ខ្លួនដោយសេរី ដោយគ្មានការត្រួតពិនិត្យជាមុនលើការផ្សព្វផ្សាយព័ត៌មានរបស់ពួកគេឡើយ ហើយពួកគេអាចរក្សាការសម្ងាត់ចំពោះប្រភពព័ត៌មានរបស់ពួកគេបាន។

១៨. ក្រសួងព័ត៌មានអាចផ្តល់អាជ្ញាប័ណ្ណ ចំពោះការងារពាក់ព័ន្ធនឹងសារពត៌មាន នៅកម្ពុជាឱ្យតែអ្នកវិជ្ជាជីវៈសារព័ត៌មានទាំងនោះអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។ ផ្ទុយទៅវិញ ក្រសួងនេះមានសិទ្ធិព្យួរ ឬលុបចោលអាជ្ញាប័ណ្ណ ប្រសិនបើក្រសួងរកឃើញថា អង្គភាព ឬអ្នកសារព័ត៌មានទាំងនោះបានរំលោភច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចព្រមព្រៀងដែលមាននៅក្រសួងព័ត៌មាន។

## ១៣. ច្បាប់ស្តីពីសហជីព (អនុសាសន៍លេខ ១៣៩.១៥៤)

១៩. ច្បាប់ស្តីពីសហជីពត្រូវបានធ្វើវិសោធនកម្មរួចហើយ កាលពីឆ្នាំ២០២០ (ដោយធ្វើវិសោធនកម្មចំពោះមាត្រាចំនួន ១០) រួមទាំងវិសោធនកម្មចំពោះការចុះបញ្ជីសហជីព និងសមាគមនិយោជក។ ការបង្កើតច្បាប់ស្តីពីសហជីពនៅឆ្នាំ២០១៦ និងវិសោធនកម្មច្បាប់នៅឆ្នាំ២០២០ គឺជាលទ្ធផលនៃដំណើរការពិគ្រោះយោបល់ត្រីភាគីជាច្រើនលើកច្រើនសាជាមួយដៃគូសង្គម ជាពិសេស ជាមួយសហជីព និងសមាគមនិយោជក ក្រោមកិច្ចគាំទ្របច្ចេកទេសពីអង្គការពលកម្មអន្តរជាតិ។ ក្នុងការធ្វើវិសោធនកម្មនេះ នីតិវិធីសម្រាប់ការចុះបញ្ជីសហជីព ឬសមាគមនិយោជកត្រូវបានកែសម្រួលឱ្យកាន់តែងាយស្រួល ដែលមានការកែសម្រួលចំពោះបទប្បញ្ញត្តិពាក់ព័ន្ធនឹងការរក្សាការចុះបញ្ជី ការរក្សាកំណត់ត្រាហិរញ្ញវត្ថុ លក្ខណៈវិនិច្ឆ័យសម្រាប់អ្នកដឹកនាំ និងអ្នកទទួលខុសត្រូវចំពោះរដ្ឋបាលសហជីព ឬសមាគមនិយោជក លក្ខខណ្ឌដើម្បីរំលាយសហជីព ឬសមាគមនិយោជក លក្ខខណ្ឌសម្រាប់សហជីពទទួលបានឋានៈភាពជាតំណាងបំផុត ព្រមទាំងសិទ្ធិ និងតួនាទីរបស់សហជីពភាគតិចនៅក្នុងសហគ្រាសផងដែរ។ បន្ថែមលើនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញគោលការណ៍ណែនាំសំខាន់ៗចំនួន ៣ រវាងឆ្នាំ២០១៨ និងឆ្នាំ២០១៩ ដើម្បីកែសម្រួល និងសម្រួលបែបបទ និងនីតិវិធីសម្រាប់ការចុះបញ្ជីសហជីព និងសម្រាប់សហជីពទទួលបានឋានៈភាពជាតំណាងបំផុត។

## ១៤. ការចុះបញ្ជីដី និងការប្រើប្រាស់ដី (អនុសាសន៍លេខ ១៣៩.១៦៩ និង ១៣៩.១៧០)

២០. ការចុះបញ្ជីដី គឺជាអាទិភាពមួយក្នុងចំណោមអាទិភាពផ្សេងទៀតរបស់កម្ពុជា គិតត្រឹមខែឧសភា ឆ្នាំ២០២៤ អាជ្ញាធរមានសមត្ថកិច្ចបានបញ្ចប់ការចុះបញ្ជីដីចំនួន ៧លានក្បាលដី (១០០% នៃផែនការ) ក្នុងដំណាក់កាលទីមួយ ហើយបានចេញវិញ្ញាបនបត្របញ្ជាក់ម្ចាស់អចលនទ្រព្យចំនួន ៦១៦.១២២ (១២,៣២% នៃចំនួនប្រមាណ ៥លានក្បាលដី) នៅដំណាក់កាលទីពីរ។

២១. ក្រសួងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានផ្តល់តួនាទី បាន និងកំពុងអនុវត្តយន្តការសម្រាប់ការគ្រប់គ្រងតំបន់ការពារ ក្នុងលក្ខណៈមួយប្រកបដោយតម្លាភាព

គណនេយ្យភាព និងបរិយាបន្ន។ ការអនុវត្តយន្តការបែបនេះ គឺដើម្បីរៀបចំសហគមន៍តំបន់ការពារ សហគមន៍ព្រៃឈើ សហគមន៍នេសាទ ការរៀបចំតំបន់ និងការបោះបង្គោលព្រំដែនតំបន់ការពារ ដូចមានចែងនៅក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ ការចុះបញ្ជីដីរដ្ឋនៃតំបន់ការពារ។ បន្ថែមលើនេះ ព្រះរាជាណាចក្រកម្ពុជាបានយកចិត្តទុកដាក់ចំពោះការផ្សព្វផ្សាយ និងការអនុវត្តឯកសារច្បាប់ពាក់ព័ន្ធនឹងដីធ្លី និងធនធានធម្មជាតិ ដើម្បីជៀសវាងការទន្ទ្រានយកដីដោយខុសច្បាប់ និងវិវាទដីធ្លី។

## ១៥. ការធ្វើឱ្យការអប់រំបឋមសិក្សាទៅជាកាតព្វកិច្ច (អនុសាសន៍លេខ ១៣៩.១៩៧ និង ១៣៩.១៩៨)

២២. មាត្រា ៦៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាធានាការអប់រំដោយឥតគិតថ្លៃ [បឋមសិក្សា និងមធ្យមសិក្សា] រហូតដល់ថ្នាក់ទីប្រាំបួន។ ការចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សានៅកម្ពុជានៅក្នុងរយៈពេលបីឆ្នាំកន្លងទៅ មានអត្រាខ្ពស់ជាង ១០០% ដែលជាអត្រាខ្ពស់ជាងអត្រាចុះឈ្មោះចូលរៀនជាសកល។ អត្រាចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សា គឺ ១១០,៩០% នៅឆ្នាំសិក្សា ២០២១-២០២២ និង១០៣,៩០% នៅឆ្នាំសិក្សា ២០២២-២០២៣ និង ១០៤,១០% នៅឆ្នាំសិក្សា ២០២៣-២០២៤។ បន្ថែមលើនេះ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំគោលនយោបាយមួយចំនួន ដើម្បីធានាការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ព្រមទាំងឱកាសរៀនសូត្រពេញមួយជីវិត សម្រាប់ប្រជាជនគ្រប់រូប។

២៣. កម្ពុជា គឺជាប្រទេសមួយ ដែលទើបងើបពីសង្គ្រាមរ៉ាំរ៉ៃ និងអំពើប្រល័យពូជសាសន៍។ ការធានាសន្តិភាព ការអភិវឌ្ឍប្រកបដោយចីរភាព សុខុមាលភាព និងសុខភាពផ្លូវចិត្តរបស់ប្រជាពលរដ្ឋ មានសារសំខាន់ខ្លាំងណាស់។ ការដាក់ចេញច្បាប់ស្តីពីការអប់រំជាកាតព្វកិច្ច ដែលនាំឱ្យមានការដាក់ទណ្ឌកម្មចំពោះឪពុកម្តាយដែលមិនបានបញ្ជូនកូនរបស់ខ្លួនទៅសាលារៀន គឺមិនសមស្របចំពោះបរិបទបច្ចុប្បន្នរបស់កម្ពុជាឡើយ។ គោលនយោបាយលើកទឹកចិត្តឪពុកម្តាយឱ្យបញ្ជូនកូនទៅសាលារៀន និងការអនុវត្តស្តង់ដាសាលារៀនគំរូ ដោយមានការចូលរួមរបស់សហគមន៍ និងអាជ្ញាធរមូលដ្ឋាននៅក្នុងការកៀរគរកុមារឱ្យចូលរួម គឺជាអភិក្រមជំនួសកាតព្វកិច្ចរបស់ពួកគេចំពោះការអប់រំ។

## ១៦. បរិស្ថាន និងការប្រែប្រួលអាកាសធាតុ (អនុសាសន៍លេខ ១៣៩.២០៩, ១៣៩.២១០ និង ១៣៩.២១១)

២៤. ការរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (NDC) របស់កម្ពុជាដែលត្រូវបានធ្វើបច្ចុប្បន្នភាពផ្តល់ការយកចិត្តទុកដាក់ជាពិសេសចំពោះយេនឌ័រ និងក្រុមងាយរងគ្រោះ (មនុស្សចាស់ ជនមានពិការភាព) ដោយធានថា ការបន្សាំនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការកាត់

បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHGs) រួមចំណែកចំពោះសង្គមមួយដែលកាន់តែមានបរិយាបន្ន។

២៥. ក្រមបរិស្ថាន និងធនធានធម្មជាតិត្រូវបានអនុម័ត និងចុះព្រះហត្ថលេខាដោយព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់នេះលុបបំបាត់ភាពមិនច្បាស់លាស់ និងបានធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិច្បាប់មួយចំនួន ដើម្បីដោះស្រាយបញ្ហាដែលកំពុងលេចឡើង និងសម្របសម្រួលកាន់តែល្អលើការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ រួមទាំងការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា។

២៦. ក្រសួងបរិស្ថានបានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រចក្រាស្ដីពី បរិស្ថាន ឆ្នាំ២០២៣-២០២៨ ដែលស្របជាមួយនឹងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា។ យុទ្ធសាស្ត្រនេះផ្តោតជាចម្បងលើអនាគតដែលស្អាត បៃតង និងប្រកបដោយចីរភាព សម្រាប់សង្គមកម្ពុជាទាំងមូល។